អែសរ៉ា ៧:១-៨:៣៥

# ជំពូក ៧ និង ៨

***ផាទចនា*** *សង្ឃអែសរ៉ាធ្វើមាគុភូមិនិវត្តន៍*

ដូចខ្ញុំបានជម្រាបរួចមកហើយថា គម្ពីរអែសរ៉ានេះ ចែកជាពីរផ្នែក គឺផ្នែកទីមួយ ពីជំពូក១-៦ បរិយាយពីសាសន៍យូដាចំនួនប្រាំម៉ឺននាក់ ដែលត្រូវធ្វើដំណើរត្រឡប់មកទីក្រុងយេរូសាឡិមវិញ ក្រោមកិច្ចដឹកនាំរបស់លោកសូរ៉ូបាបិល។ ផ្នែកទីពីរ ពីជំពូក៧-១០ បរិយាយពីសាសន៍យូដាចំនួនពីរពាន់នាក់វិលមកនគរវិញ ក្រោមកិច្ចដឹកនាំរបស់លោកអែសរ៉ា។ សាសន៍យូដាត្រូវគេចាប់យកទៅធ្វើជាឈ្លើយ ពីព្រោះបានប្រព្រឹត្តអំពើបាបពីរយ៉ាង។ ទីមួយគឺ សាសន៍យូដាបាននាំគ្នាថ្វាយបង្គំរូបព្រះ ពោលគឺមិនបានថ្វាយបង្គំព្រះជាម្ចាស់ផ្ទាល់ទេ។ ដូច្នេះ ព្រះអង្គបញ្ជូនសាសន៍នេះ អោយទៅលត់ដំនៅឯប្រទេសដទៃ។ រីឯអំពើបាបទីពីរ គឺសាសន៍យូដាមិនគោរពតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ស្ដីពីការប្រើប្រាស់ដីធ្លីនៅក្នុងនគរទាំងមូល។ តាមក្រឹត្យវិន័យរបស់លោកម៉ូសេ ព្រះជាម្ចាស់បង្គាប់ដល់សាសន៍អ៊ីស្រាអែលអោយទុកដីទំនេររៀងរាល់ប្រាំមួយឆ្នាំ ពេលគេធ្វើស្រែចំការ។ សាសន៍យូដាដឹងច្បាប់ទម្លាប់របស់ព្រះជាម្ចាស់ តែគេមិនព្រមស្ដាប់តាមព្រះអង្គទេ។ គេគិតថា ច្បាប់តូចតាចរបស់ព្រះជាម្ចាស់យ៉ាងដូច្នេះ តើចាំបាច់ត្រូវយកមកអនុវត្តធ្វើអី? ចំពោះព្រះជាម្ចាស់ ទ្រង់មិនរាប់ច្បាប់នោះថាជា

ច្បាប់តូចតាចនោះទេ។ ព្រះអម្ចាស់បង្គាប់ថា គេចាំបាច់ត្រូវធ្វើស្រែប្រាំមួយឆ្នាំ ចោលមួយឆ្នាំ។ ដោយសារមូលហេតុនោះ ព្រះអង្គបញ្ជូនគេអោយទៅធ្វើជាខ្ញុំគេ ចំនួនចិតសិបឆ្នាំ ពីព្រោះព្រះអង្គចង់អោយដីនៅក្នុងនគរបានសម្រាកពីការកាប់គាស់។ បន្ទាប់ពីទទួលទោសអស់រយៈពេលចិតសិបឆ្នាំហើយ គេមានសិទ្ធិត្រឡប់មកនគររបស់គេវិញ។

មុនពេលសាសន៍យូដាត្រឡប់មកស្រុកវិញ គេមានការភ្ញាក់រឭកខាងព្រលឹងវិញ្ញាណចំនួនពីរដង។ លើកទីមួយ គឺជាការភ្ញាក់រឭកក្រោមការដឹកនាំរបស់សង្ឃអែសរ៉ា តែសង្ឃអង្គនេះ មិនបានអញ្ជើញមកលើកទីមួយទេ។ នៅលើកទីមួយ មានប្រជាពលរដ្ឋចំនួនប្រាំម៉ឺននាក់ សុខចិត្តធ្វើដំណើរត្រឡប់មកស្រុកកំណើតរបស់ខ្លួនវិញក្រោមការដឹកនាំរបស់លោកសូរ៉ូបាបិល។ ចំណែកសង្ឃអែសរ៉ា នៅបង្ហាត់បង្រៀនព្រះបន្ទូលព្រះដល់សាសន៍យូដាតទៅទៀត នៅប្រទេសបាប៊ីឡូន។ ប្រមាណជាងចិតសិបឆ្នាំក្រោយមក មានការភ្ញាក់រឭកខាងព្រលឹងវិញ្ញាណម្តងទៀត។ ពេលនោះមានមនុស្សចំនួន២០០០នាក់ ព្រមធ្វើដំណើរត្រឡប់មកវិញជាមួយនឹងសង្ឃអែសរ៉ា។ សង្ឃអែសរ៉ាកត់ត្រាទុកព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រសម្រាប់សាសន៍អ៊ីស្រាអែល ត្រង់ចំណុចនេះ លោកមិនបានកត់ត្រាទុកតាមលំដាប់លំដោយពេលវេលា និងព្រឹត្តិការណ៍ទេ។ នៅក្នុងបួនជំពូកចុងក្រោយនៃកណ្ឌព្រះគម្ពីរអែសរ៉ា យើងជួបជាមួយនឹងអ្នកនិពន្ធផ្ទាល់តែម្តង។ ជំពូក៧ និងជំពូក៨ សង្ឃអែសរ៉ានាំសាសន៍យូដាត្រឡប់មកស្រុកកំណើតវិញ។ ជំពូក៩ និងជំពូក១០ សង្ឃអែសរ៉ាបាននាំអោយមានចលនាបដិវត្តន៍

ក្នុងកិច្ចប្រតិបត្តិសាសនាយូដា។ ការភ្ញាក់រឭកខាងព្រលឹងវិញ្ញាណ តែងតែបណ្តាលអោយមានការបដិវត្តន៍នៅក្នុងការប្រតិបត្តិសាសនា។ ការបដិវត្តន៍សាសនា មិនមែនជាការប្តូរផ្លាស់សាសនាទេ គ្រាន់តែធ្វើអោយពលរដ្ឋគោរពសាសនាកាន់តែខ្លាំងឡើង។ ប៉ុន្តែ មុននឹងមានការធ្វើបដិវត្តន៍សាសនា ចាំបាច់ត្រូវមានការភ្ញាក់រឭកខាងវិញ្ញាណជាមុន។ នៅពេលយើងសិក្សាព្រះគម្ពីរនេហេមា យើងនឹងឃើញលំដាប់ហេតុការណ៍បែបនោះ ដូចរៀបរាប់ជូនខាងលើ។

សង្ឃអែសរ៉ាជាតួអង្គសំខាន់មួយរូប ដែលគេតែងតែបំភ្លេចលោកចោលនៅក្នុងព្រះគម្ពីរ។ គ្រូអធិប្បាយ គ្រូគង្វាល ឬគ្រូបកស្រាយគម្ពីរ មិនបានទទួលស្គាល់គុណូបការៈរបស់សង្ឃអែសរ៉ា អោយសមនឹងកេរ្តិ៍ឈ្មោះ ព្រមទាំងកិច្ចការដែលលោកបានបំពេញឡើយ។ នៅក្នុងក្រុមជំនុំក៏គេមិនសូវនឹកឃើញពីលោកដែរ។ ដោយសារមានគេជាច្រើនបោះបង់ចោលលោក យើងនឹងសិក្សាអំពីបុគ្គលិកលក្ខណៈរបស់លោក ក្នុងការសិក្សារបស់យើង ពិសេសក្នុងវគ្គទីពីរ គឺគម្ពីរអែសរ៉ាពីជំពូក៧-១០។

> **[១]ក្រោយការទាំងនោះមក ក្នុងរាជ្យអើថាសើកសេស ជាស្តេច**
> **ពើស៊ី នោះអែសរ៉ា កូនសេរ៉ាយ៉ា ដែលជាកូនអ័សារា ជាកូន**
> **ហ៊ីលគីយ៉ា [២]ហ៊ីលគីយ៉ា ជាកូនសាលូម សាលូមជាកូនសាដុក**
> **ជាកូនអ័ហ៊ីទូប [៣]អ័ហ៊ីទូប ជាកូនអ័ម៉ារា ជាកូនអ័សារា ជាកូន**
> **មេរ៉ាយ៉ូត [៤]មេរ៉ាយ៉ូត ជាកូនសេរ៉ាហា ជាកូនអ៊ូស៊ី ជាកូនប៊ូកគី**

**[៥]ប៊ូកគី ជាកូនអ័ប៊ីសួរ។ ជាកូនភីនេហាស។ ជាកូនអេលាសារ។ ជាកូនអើរ៉ុនដ៏ជាសំដេចសង្ឃ (អែសរ៉ា៧:១-៥)។**

តើព្រះរាជាអើថាសើកសេស ជាស្តេចអង្គណា? ព្រះបាទអើថាសើកសេសជាព្រះចៅក្រុងពើស៊ី។ ស្តេចអង្គនេះបានប្រទានការអនុញ្ញាតអោយហោរានេហេមាត្រឡប់មកសាងសង់កំផែងទីក្រុងយេរូសាឡិមឡើងវិញ។ ការនេះ គឺជាការសម្រេចបទទំនាយ ដែលហោរាដានីយ៉ែលបានទាយទាក់ទងនឹងរយៈពេលចំនួនចិបសិបសប្តាហ៍ស្តីពីសាសន៍អីស្រាអែល។ យើងនឹងសិក្សារឿងនោះអោយបានល្អិតល្អន់ពេលយើងពិចារណាព្រះបន្ទូលក្នុងកណ្ឌព្រះគម្ពីរនេហេមា។

ប៉ុន្តែ បុគ្គលដែលខ្ញុំយកចិត្តទុកដាក់មិនមែនអើថាសើកសេសទេ គឺសង្ឃអែសរ៉ាវិញ។ តើសង្ឃអែសរ៉ាជានរណា? សង្ឃអែសរ៉ាជាពូជពង្សរបស់សង្ឃមួយរូបនាមភីនេហាស។ សង្ឃភីនេហាសត្រូវជាចៅរបស់សម្តេចសង្ឃអើរ៉ុន។ សង្ឃអែសរ៉ាកើតមកក្នុងត្រកូលពួកសង្ឃ។ បើសិនជាព្រះវិហារទីក្រុងយេរូសាឡិមមាននៅឡើយ សង្ឃអែសរ៉ាប្រហែលជាត្រូវបម្រើការងារនៅទីនោះ ក្នុងងារជាសម្តេចសង្ឃផង។ លោកមិនបានបម្រើតួនាទីជាសង្ឃក្នុងព្រះវិហារទីក្រុងយេរូសាឡិម ដ្បិតវិហារនេះត្រូវគេបំផ្លាញខ្ទេចខ្ទីអស់ទៅ។

ការធ្វើមាតុភូមិនិវត្តន៍លើកទីមួយ សង្ឃអែសរ៉ាយល់ថា លោកមិនគួរត្រឡប់មកទីក្រុងយេរូសាឡិម។ ឯមូលហេតុនោះគឺ នៅក្នុងទីក្រុងយេរូសាឡិមមិនទាន់មាន

ព្រះវិហារនៅឡើយ។ ទំរាំដល់ពេលព្រះវិហារសង់រួច ហោរាអែសរ៉ាត្រូវបង្ហាត់បង្រៀន ដល់សាសន៍យូដា ដែលតាំងទីលំនៅក្នុងទឹកដីថ្មីនៃប្រទេសបាប៊ីឡូន។ ក្នុងពេលនេះ ហោរាអែសរ៉ាបាននាំសាសន៍យូដាចំនួន២០០០នាក់ ធ្វើដំណើរត្រឡប់មកទីក្រុង យេរូសាឡិមវិញ។ ក្រុមនេះ ជាក្រុមដែលត្រូវត្រឡប់មកទីក្រុងយេរូសាឡិមវិញ ជាលើក ជាទីពីរ។ ព្រះវិហារបានសាងសង់រួចជាស្រេច ដូច្នេះ លោកមានកន្លែងសម្រាប់ បម្រើដល់ព្រះជាម្ចាស់ និងដល់ពលរដ្ឋអ៊ីស្រាអែលហើយ។ សង្ឃអែសរ៉ាមិនមែនគ្រាន់ តែជាអ្នកនាំពួកសាសន៍យូដាត្រឡប់មកស្រុកកំណើតវិញទេ លោកជាគ្រូបង្រៀន ព្រះបន្ទូលរបស់ព្រះថែមទៀតផង។

លោកភីនេហាសត្រូវជាកូនរបស់សង្ឃអេលាសារ ពោលគឺត្រូវជាចៅរបស់ សម្ដេចសង្ឃអើរ៉ុន។ លោកភីនេហាសឡើងធ្វើជាសង្ឃ ពេលសាសន៍អ៊ីស្រាអែលនាំ គ្នាប្រព្រឹត្តប្រាសចាកពីការថ្វាយបង្គំព្រះដ៏ពិត ទៅថ្វាយបង្គំរូបព្រះជំនួសវិញ។ សង្ឃ ភីនេហាសមានចិត្តឧស្សាហ៍ចំពោះព្រះជាម្ចាស់ណាស់ បានជាលោកចាំបាច់ត្រូវ វិនិច្ឆ័យរឿងក្ដីរបស់អ៊ីស្រាអែល ដើម្បីអោយសាសន៍អ៊ីស្រាអែលត្រឡប់មកថ្វាយបង្គំ ព្រះជាម្ចាស់ជាព្រះដ៏រស់ ដែលបានសង្គ្រោះគេវិញ។ រឿងនេះ ទាក់ទងជាមួយនឹង ហោរាបាឡាំម ដែលស្ដេចបាឡាក់ជួលទៅដាក់បណ្ដាសាដល់សាសន៍អ៊ីស្រាអែល។ ដោយសារហោរាបាឡាំមមិនអាចដាក់អំពើអំពាន់ អាបធ្មប់ ឬដាក់បណ្ដាសាដល់សាសន៍ អ៊ីស្រាអែលបាន ហោរារូបនេះ បានបង្ហាត់បង្រៀនអោយស្ដេចបាឡាក់ប្រើសង្គ្រាម ត្រជាក់ ដើម្បីទាក់ទាញសាសន៍អ៊ីស្រាអែល។ ស្ដេចបាឡាក់ចេះល្បិចសម្ងាត់នោះ

ក៏បប្អូលក្រមុំរបស់សាសន៍អ៊ីស្រាអែលអោយមកយកប្ដីជាពលរដ្ឋរបស់លោក ឯកូនក្រមុំរបស់លោក លោកអោយទៅកូនកម្លោះរបស់សាសន៍អ៊ីស្រាអែល។ ដោយសារវិធីនោះ សាសន៍អ៊ីស្រាអែលជារាស្ត្ររបស់ព្រះអង្គបានទទួលការវក់វី និងសេចក្ដីប៉ងប្រាថ្នារបស់លោកីយ៍ របស់សាច់ឈាម ហើយនិងអំពើអាក្រក់។ រឿងសង្ឃភីនេហាសជំនុំជំរះដល់សាសន៍អ៊ីស្រាអែល មានបរិយាយនៅក្នុងគម្ពីរជនគណនា២៥:៧-១១។ នៅក្នុងបរិបទនេះ បុរសសាសន៍អ៊ីស្រាអែលមួយរូបបានយកស្ត្រីសាសន៍ម៉ាឌានម្នាក់មកធ្វើជាភរិយា។ ដោយសារសាសន៍យូដាទៅរៀបការជាមួយនឹងស្ត្រីមួយរូបដែលមិនស្គាល់ព្រះជាម្ចាស់ ស្ត្រីនោះអន្ទងប្ដីអោយទៅថ្វាយបង្គំរូបព្រះរបស់គេ។ ដោយសារមូលហេតុនោះ ព្រះជាម្ចាស់បានបណ្ដាលអោយសាសន៍អ៊ីស្រាអែលទទួលការវេទនាយ៉ាងខ្លាំង។ សង្ឃភីនេហាសចាំបាច់ត្រូវបង្អាក់ការវេទនាដែលត្រូវកើតឡើងដល់ជនជាតិរបស់លោក។ លោកបានរកឃើញថា មានបុរសសាសន៍យូដាម្នាក់ យកស្ត្រីសាសន៍ម៉ាឌានមកធ្វើជាភរិយា។ ដូច្នេះ លោកក៏ប្រហារជីវិតដល់បុរសសាសន៍យូដា និងស្ត្រីសាសន៍ម៉ាឌាននោះចោលទៅ។ ការប្រហារជីវិតដល់ជនឧក្រិដ្ឋពីររូបធ្វើអោយពលរដ្ឋសាសន៍អ៊ីស្រាអែលជាច្រើនលាននាក់ ទទួលសេចក្ដីសុខសាន្តនៅក្នុងសង្គម។ ព្រះជាម្ចាស់ពេញព្រះទ័យ និងកិរិយាប្រព្រឹត្តរបស់ភីនេហាស បានជាព្រះអង្គសន្យាថានៅក្នុងពូជពង្សរបស់សង្ឃអង្គនេះ នឹងមានមនុស្សបម្រើជាសង្ឃដ៏អស់កល្បជានិច្ចតរៀងទៅ។

ទាក់ទងនឹងសេចក្ដីពិតខាងលើ ខ្ញុំចង់បញ្ជាក់ជំហរសារជាថ្មីម្ដងទៀត នូវព្រះ

បន្ទូលរបស់ព្រះជាម្ចាស់ស្តីពីការកាត់ទោសប្រហារជីវិតដល់ជនឧក្រិដ្ឋ។ ក្នុងពេលបច្ចុប្បន្ននេះ ចៅក្រមនៅប្រទេសជាច្រើនយល់ថា ការកាត់ទោសប្រហារជីវិតដល់ជនឧក្រិដ្ឋ ជាអំពើយង់ឃ្នង។ ដូច្នេះហើយ បានជាគេបំបាត់ច្បាប់នោះចេញពីនគរ។ បុព្វហេតុចម្បងបង្អស់នៃការកាត់ទោសប្រហារជីវិតដល់ជនឧក្រិដ្ឋ គឺដើម្បីការពារដល់ប្រជាពលរដ្ឋស្លូតត្រង់។ ការកាត់ទោសប្រហារជីវិតជនឧក្រិដ្ឋមួយរូប បណ្តាលអោយជីវិតរបស់ប្រជាពលរដ្ឋរាប់លាននាក់មានសេចក្តីសុខសាន្ត។ នៅក្នុងសង្គមរបស់យើងសព្វថ្ងៃ ប្រជាពលរដ្ឋរស់នៅដោយភ័យខ្លាចរៀងរាល់វិនាទី។ មុនថ្ងៃលិចប្រជាពលរដ្ឋតែងតែគិតថា យប់នេះ ប្រហែលជាមានចោរចូលលួចប្លន់ គាស់ផ្ទះសម្ល៉េង លួចមាន់លួចគោ លួចជ្រូកជាដើម។ លុះពេលថ្ងៃរះឡើង មុននឹងគេចេញដំណើរទៅក្រៅគេគិតថា គេអាចទទួលគ្រោះថ្នាក់ចរាចរ ឬគ្រោះថ្នាក់ណាមួយដែលជនមិនស្គាល់ច្បាប់បង្កឡើង។ តើអសន្តិសុខនៅក្នុងសង្គមដែលកើតឡើងមានសព្វថ្ងៃនេះ បណ្តាលមកពីបុព្វហេតុអ្វី? រឿងនេះទាក់ទងជាមួយនឹងការលើកចោលនូវការកាត់ទោសប្រហារជីវិតដល់ជនឧក្រិដ្ឋ។ បើសង្គមណាមួយអនុវត្តការកាត់ទោសប្រហារជីវិតដោយយុត្តិធម៌ត្រឹមត្រូវ អំពើឧក្រិដ្ឋនៅក្នុងសង្គមនោះពិតជាថយចំនួនជាអតិបរមា។ បើលោកអ្នកមិនជឿសូមសាកល្បងខ្លួនឯងលមើលចុះ។ នៅលើផ្លូវដែលប៉ូលីសចរាចរដាក់សញ្ញាថាហាមបត់ឆ្វេង បើលោកអ្នកបត់ឆ្វេង លោកអ្នកច្បាស់ជាត្រូវបង់លុយកាហ្វេគុយទាវអោយប៉ូលីសសិនជាមិនខាន។ ចំណុចដែលខ្ញុំចង់និយាយនេះ គឺការកាត់ទោសប្រហារជីវិតដល់ជនឧក្រិដ្ឋ ពិតជាធ្វើអោយឧក្រិដ្ឋកម្មថយចំនួនច្រើនជាអតិបរមា។ សាសន៍

យូដារួចជីវិតជាច្រើនលាននាក់ ដោយសារសង្ឃភីនេហាសបានកាត់ទោសប្រហារជីវិតជនពីររូប ដែលបំពានលើច្បាប់រដ្ឋ។ ដោយសារជនឧក្រិដ្ឋពីររូបនេះ ត្រូវទទួលការកាត់ទោសប្រហារជីវិត សាសន៍អ៊ីស្រាអែលរាប់លាននាក់បានរស់នៅដោយសុខសាន្ត។

នៅក្នុងសង្គម ហេតុអ្វីបានជាចាំបាច់ត្រូវមានការកាត់ទោសប្រហារជីវិត? ដើម្បីឆ្លើយនឹងសំណួរនេះ ខ្ញុំចង់អោយជនដែលទទួលការកាត់ទោសប្រហារជីវិតឆ្លើយខ្លួនឯងចុះ។ មុននឹងគេយកជនទុច្ចរិតមួយរូបទៅព្យួរកគេសួរលោកថា "តើលោកមានអារម្មណ៍យ៉ាងណាដែរ ពេលគេព្យួរកលោក?" លោកឆ្លើយថា "ខ្ញុំចង់អោយសាធារណជនដឹងថា មេរៀននេះល្អសម្រាប់ខ្ញុំ"។ លោកអ្នកបងប្អូនអើយ បុព្វហេតុនៃការព្យួរកជនឧក្រិដ្ឋមួយរូបនេះ មិនមែនជាមេរៀនសម្រាប់អ្នកស្លាប់ទេ គឺជាការការពារដល់ជីវិតរបស់អ្នកស្លូតត្រង់ ដែលចង់រស់នៅដោយសុខសាន្តនៅក្នុងនគរ។ ក្នុងពេលសព្វថ្ងៃ តើហេតុអ្វីបានជាយើងមិនព្រមប្រឈមមុខជាមួយនឹងបញ្ហានេះ? ហេតុអ្វីបានជាយើងចាំបាច់ត្រូវអោយមនុស្សរាប់រយ រាប់ពាន់ រាប់ម៉ឺន រាប់លាននាក់ស្លាប់ ដើម្បីការពារជនឧក្រិដ្ឋមួយរូប? ព្រះជាម្ចាស់មិនអោយការពារជីវិតរបស់ជនឧក្រិដ្ឋមួយរូប ដើម្បីរក្សាអោយជនស្លូតត្រង់អាចរស់នៅដោយសុខសាន្ត។ ព្រះជាម្ចាស់បង្គាប់អោយតុលាការកាត់ទោសប្រហារជីវិតដល់ជនឧក្រិដ្ឋ ពីព្រោះទ្រង់ជ្រាបពីអំពើអាក្រក់ ដែលកើតមាននៅក្នុងចិត្តរបស់មនុស្សគ្រប់រូប។ គម្ពីរយេរេមា១៧:៩ សម្តែងថា "ឯចិត្តជាគ្រឿងបញ្ឆោតលើសជាងទាំងអស់ ហើយក៏អាក្រក់ហួសល្បត់ផង តើអ្នកណានឹងអាចស្គាល់បាន"។ ហេតុការណ៍ដែលសង្ឃភីនេហាសបានប្រហារជីវិតដល់ជនឧក្រិដ្ឋពីររូប

បន្សល់ទុកនូវមេរៀនសម្រាប់យើងយកមកប្រើក្នុងសម័យសព្វថ្ងៃនេះ។ សង្ឃភីនេហាស គឺជាព្ធយុកោរបស់សង្ឃអែសរ៉ា។

> **អែសរ៉ានេះ លោកឡើងមកពីក្រុងបាប៊ីឡូន លោកជាស្មៀនស្ទាត់ជំនាញខាងក្រឹត្យវិន័យលោកម៉ូសេ ដែលព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលបានប្រទានមក ហើយដោយព្រោះព្រះហស្តនៃព្រះយេហូវ៉ា ជាព្រះនៃលោក បានសណ្ឋិតលើលោក បានជាស្តេចទ្រង់អនុញ្ញាតគ្រប់ទាំងសេចក្តីដែលលោកសូម (អែសរ៉ា ៧:៦)។**

នៅក្នុងខនេះ យើងឃើញថា សង្ឃអែសរ៉ាជាស្មៀនយ៉ាងស្ទាត់ជំនាញខាងក្រឹត្យវិន័យលោកម៉ូសេ។ នៅគ្រាដែលលោកស្នាក់នៅក្នុងប្រទេសបាប៊ីឡូន លោកមិនបានបំពេញតួនាទីរបស់លោកជាសង្ឃអោយបានពេញលេញទេ ដ្បិតទីនោះគ្មានព្រះវិហារ។ ផ្ទៀតឱកាសនោះ លោកបានសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់បានហ្មត់ចត់ជាទីបំផុត។ ឥឡូវ ពេលលោកត្រឡប់មកប្រទេសអ៊ីស្រាអែលវិញ លោកអាចយកចំណេះចេះដឹងទាំងអម្បាលមាណ ដែលលោកបានសិក្សាមកអនុវត្ត។ ក្នុងគម្ពីរអែសរ៉ា ៧:២១ យើងឃើញថា សង្ឃអែសរ៉ាមានកេរ្តិ៍ឈ្មោះល្បីល្បាញយ៉ាងខ្លាំងនៅក្នុងប្រទេសបាប៊ីឡូន។ សូម្បីនៅក្នុងព្រះរាជវាំង ឈ្មោះរបស់លោកក៏មានការល្បីល្បាញនៅទីនោះ

ដែរ។ គេនាំគ្នាដាក់ងារលោកថា ជាស្មៀនចម្លងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នាទីរបស់លោក គឺជាគ្រូបង្ហាត់បង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ដល់ព្រះជាពលរដ្ឋ។

> **ក៏មានពួកកូនចៅអ៊ីស្រាអែល ពួកសង្ឃ ពួកលេវី ពួកចំរៀង ពួកឆ្មាំទ្វារ នឹងពួកនេធីនិមខ្លះ ឡើងទៅឯក្រុងយេរូសាឡិម នៅឆ្នាំទី៧ ក្នុងរាជ្យស្តេចអើថាសើកសេសដែរ (អែសរ៉ា៧:៧)។**

មុនគ្រាដែលសង្ឃអែសរ៉ាត្រឡប់មកស្រុកអ៊ីស្រាអែលវិញ នៅក្នុងចំណោមសាសន៍យូដា មានការភ្ញាក់រឭកខាងព្រលឹងវិញ្ញាណម្តងទៀត ពេលគេស្នាក់នៅក្នុងប្រទេសបាប៊ីឡូន។ ដូច្នេះហើយ បានជាមានចំនួនមនុស្ស២០០០នាក់ ព្រមធ្វើមាតុភូមិនិវត្តន៍ជាមួយនឹងសង្ឃអែសរ៉ា។

> **៨លោកបានមកដល់ក្រុងយេរូសាឡិម ក្នុងខែស្រាពណ៍នៅឆ្នាំទី៧
> ក្នុងរាជ្យស្តេចនោះ ៩ដ្បិតលោកបានចេញពីក្រុងបាប៊ីឡូននៅថ្ងៃ១
> ខែចេត្រ ក៏មកដល់ក្រុងយេរូសាឡិមនៅថ្ងៃ១ខែស្រាពណ៍ ដោយ
> ព្រះហស្តល្អរបស់ព្រះនៃលោក បានសណ្ឋិតលើលោក (អែសរ៉ា៧:
> ៨-៩)។**

សង្ឃអែសរ៉ា និងប្រជាពលរដ្ឋ២០០០នាក់ ធ្វើដំណើរត្រឡប់មកទីក្រុងយេរូសាឡិមវិញ ក្នុងឆ្នាំទីប្រាំពីរនៃរាជ្យរបស់ព្រះបាទអើថាសើកសេស ព្រះចៅក្រុងពើស៊ី។ ការត្រឡប់មកស្រុកកំណើតវិញ ត្រូវធ្វើដំណើរអស់រយៈពេលប្រាំខែ។ ដំណើរនោះមានការលំបាកលំបិន ព្រមទាំងប្រើរយៈពេលយូរណាស់។

**ពីព្រោះអែសរ៉ា បានតាំងចិត្តស្វែងរកក្នុងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា ដើម្បីនឹងប្រព្រឹត្តតាម ហើយបង្ហាត់បង្រៀនតាមបញ្ញត្ត និងសេចក្តីយុត្តិធម៌ក្នុងពួកអ៊ីស្រាអែល (អែសរ៉ា៧:១០)។**

សង្ឃអែសរ៉ាបានត្រៀមចិត្តរបស់លោក ដើម្បីធ្វើដំណើរយ៉ាងវែងឆ្ងាយត្រឡប់មកស្រុកកំណើតវិញ។ ការធ្វើដំណើរនេះ គឺជាការទុកចិត្តដល់ព្រះជាម្ចាស់ទាំងស្រុង។ លោកបានសិក្សាព្រះបន្ទូល ដែលមានសរសេរនៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ គឺគម្ពីរបញ្ចក័ណ្ឌ ព្រមទាំងគម្ពីរយ៉ូស្វេ ដែលជាក័ណ្ឌគម្ពីរមាននៅក្នុងសម័យនោះ។ សង្ឃអែសរ៉ាកត់ត្រាទុកនូវក័ណ្ឌព្រះគម្ពីរ១របាក្សត្រ និង២របាក្សត្រ។ សង្ឃអង្គនេះមិនគ្រាន់តែសិក្សាអោយចេះព្រះបន្ទូលប៉ុណ្ណោះទេ គឺលោកអនុវត្តព្រះបន្ទូល ដែលលោកចេះថែមទៀតផង។ ការអនុវត្តន៍ព្រះបន្ទូលមានសារៈសំខាន់ស្មើនឹងការសិក្សាព្រះបន្ទូល។ សង្ឃអែសរ៉ាមានចិត្តចង់បង្ហាត់បង្រៀនព្រះបន្ទូលដល់ពួកបណ្តាជន។ លោកចង់អោយបណ្តាជនដឹងពីល័ក្ខខ័ណ្ឌ ដែលត្រូវរស់នៅក្នុងនាមជារាស្ត្ររបស់

ព្រះជាម្ចាស់ ព្រមទាំងទោសដែលត្រូវទទួល បើគេមិនធ្វើតាមព្រះបន្ទូលរបស់ព្រះអង្គ។

> **១១ នេះជាសំណៅពីសំបុត្រ ដែលអើថាសើកសេស ដ៏ជាស្តេចទ្រង់**
> **បានប្រទានដល់អែសរ៉ាដ៏ជាសង្ឃ ជាស្មៀនចំឡងអស់ទាំង**
> **ព្រះបន្ទូល ក្នុងក្រិត្យក្រមទាំងប៉ុន្មាននៃព្រះយេហូវ៉ា នឹងបញ្ញត្តនៃ**
> **ទ្រង់ ដល់ពួកអ៊ីស្រាអែល មានសេចក្តីថា ១២ អើថាសើកសេស ជា**
> **ស្តេចលើអស់ទាំងស្តេច ប្រទានដល់អែសរ៉ាដ៏ជាសង្ឃ ជាស្មៀន**
> **ចំឡងក្រិត្យវិន័យរបស់ព្រះនៃស្ថានសួគ៌។ល។ ១៣ យើងចេញ**
> **ព្រះរាជឱង្ការថា ឯអស់អ្នកណាក្នុងពួកសាសន៍អ៊ីស្រាអែល ឬពួក**
> **សង្ឃ នឹងពួកលេវី នៅក្នុងនគរយើង ដែលចង់ទៅឯក្រុងយេរូ**
> **សាឡិម ជាមួយនឹងអ្នក ដោយស្ម័គ្រពីចិត្ត នោះចូរឱ្យគេទៅចុះ**
> **(អែសរ៉ា៧:១១-១៣)។**

ព្រះបាទអើថាសើកសេស ព្រះចៅក្រុងពើស៊ីបានចេញព្រះរាជក្រឹត្យមួយថ្មីទៀត អនុញ្ញាតសង្ឃអែសរ៉ា និងសិស្សរបស់លោកអាចធ្វើដំណើរត្រឡប់មកប្រទេសអ៊ីស្រាអែលវិញ។ នៅក្នុងព្រះរាជក្រឹត្យ ស្តេចនេះមិនបានបញ្ជាអោយសាសន៍អ៊ីស្រាអែលគ្រប់រូប ត្រូវតែធ្វើដំណើរមកស្រុកកំណើតវិញទេ។ ស្តេចអង្គនេះគ្រាន់តែអនុញ្ញាតអោយសាសន៍អ៊ីស្រាអែលណា ដែលមានចិត្តចង់មកស្តារនគររបស់ខ្លួនឡើងវិញ ព្រម

ទាំងជាអ្នកដែលដឹងច្បាស់ថា ព្រះជាម្ចាស់បានត្រាស់ហៅគេអោយត្រឡប់មកនគរគេ។

> **[១៤]ពីព្រោះស្ដេច នឹងពួកសេនាបតីទាំង៧ បានចាត់អ្នកឱ្យទៅត្រួត**
> **ត្រាមើល ក្នុងស្រុកយូដា នឹងក្រុងយេរូសាឡិម តាមក្រិត្យវិន័យ**
> **របស់ព្រះនៃអ្នក ជាច្បាប់ដែលនៅក្នុងកណ្ដាប់ដៃអ្នក [១៥]ហើយឱ្យ**
> **នាំយកប្រាក់ នឹងមាស ដែលយើង ជាស្ដេច នឹងពួកសេនាបតី**
> **ទាំង៧ បានថ្វាយស្ម័គ្រពីចិត្ត ដល់ព្រះនៃសាសន៍អ៊ីស្រាអែល ជា**
> **ព្រះដែលគង់នៅក្រុងយេរូសាឡិម (អែសរ៉ា៧:១៤-១៥)។**

លោកអែសរ៉ាជាសង្ឃដែលមានកេរ្តិ៍ឈ្មោះល្អល្បីល្បាញនៅក្នុងព្រះរាជវាំង ក៏ដូចជានៅក្នុងនគរពើស៊ីទាំងមូល។ ដូច្នេះហើយ បានជាស្ដេចអើថាសើកសេស បានសូមអោយសេនាបតីរបស់លោក ថ្វាយដង្វាយដល់ព្រះនៃសាសន៍អ៊ីស្រាអែល តាមរយៈសង្ឃអែសរ៉ា។ ស្ដេចបង្គាប់អោយសង្ឃអែសរ៉ាមានសិទ្ធិតែងតាំងចៅហ្វាយក្រុង និងពួកចៅក្រម ដែលត្រូវធ្វើអោយមានសណ្ដាប់ធ្នាប់ក្នុងសង្គមនៅក្នុងទីក្រុងយេរូសាឡិម។ មិនតែប៉ុណ្ណោះ ស្ដេចបានចេញព្រះរាជក្រឹត្យអោយនាំមកនូវទ្រព្យសម្បត្តិជាច្រើនសម្រាប់ធ្វើការសាងសង់ទីក្រុងយេរូសាឡិម និងបញ្ចប់កិច្ចការនៅក្នុងព្រះវិហារ។ សេចក្ដីដែលមានចែងនៅក្នុងព្រះរាជក្រឹត្យសបញ្ជាក់អោយឃើញថា មានការកោតខ្លាចដល់ព្រះជាម្ចាស់យ៉ាងខ្លាំង។ ព្រះរាជក្រឹត្យនោះ បញ្ចប់នូវសេចក្ដីដូចខាងក្រោមនេះ :

**ឯអ្នកណាដែលមិនព្រមប្រព្រឹត្តតាមក្រឹត្យវិន័យ របស់ព្រះនៃអ្នក ហើយនឹងច្បាប់របស់ស្តេចផង នោះត្រូវតែកាត់ទោសជាប្រញាប់ចុះ ទោះដល់ស្លាប់ ឬនិរទេស ឬរឹបយករបស់ទ្រព្យគេ ឬដាក់គុកក្តី (អែសរ៉ា៧:២៦)។**

ច្បាប់ទាំងនេះ គឺជាច្បាប់ទាក់ទងនឹងសាសន៍យូដា បន្ទាប់ពីគេត្រឡប់មកដល់ស្រុកកំណើតរបស់ខ្លួនវិញ។ ព្រះរាជក្រឹត្យបញ្ជាក់ថា នៅពេលសាសន៍យូដាត្រឡប់មកដល់នគរខ្លួន គេចាំបាច់ត្រូវរក្សាទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់ ជាព្រះដ៏រស់ជាប្រចាំ។

ខាងក្រោមនេះ សង្ឃអែសរ៉ាបានថ្វាយពាក្យអរព្រះគុណដល់ព្រះជាម្ចាស់ ដោយការរបស់ទ្រង់ដែលបានធ្វើចំពោះលោក។

**សូមសរសើរដំកើងដល់ព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោយើងរាល់គ្នា ដែលទ្រង់បានបណ្តាលព្រះទ័យស្តេច ឲ្យសំរេចនឹងតាក់តែងព្រះវិហារនៃព្រះយេហូវ៉ា ដែលនៅក្រុងយេរូសាឡិមឲ្យល្អឡើងដូច្នេះ (អែសរ៉ា៧:២៧)។**

ព្រះវិហារទីក្រុងយេរូសាឡិមបានសាងសង់ចប់សព្វគ្រប់ ព្រមទាំងបានតុប

តែងយ៉ាងល្អប្រណីតថែមទៀតផង។ ការសាងសង់ព្រះវិហារលើកនេះ មិនកំណត់ធនធានដើម្បីបញ្ចប់កិច្ចការនោះទេ។ ដូច្នេះ គេអាចប្រើធនធានជាច្រើន ដែលគេអាចធ្វើការកែលំអដល់វិហារនោះ។

> **ព្រមទាំងប្រោសផ្តល់សេចក្តីសប្បុរសរបស់ទ្រង់ ដល់ខ្ញុំនៅចំពោះស្តេច ពួកសេនាបតីទ្រង់ ហើយពួកអ្នកប្រធានដ៏មានអំណាចរបស់ស្តេចផង ខ្ញុំក៏មានកំឡាំងចំរើនឡើង ដោយនូវព្រះហស្តនៃព្រះយេហូវ៉ា ជាព្រះនៃខ្ញុំ ដែលសណ្ឋិតលើខ្ញុំ ហើយខ្ញុំបានទៅប្រមូលពួកអ្នក ដែលជាកំពូលក្នុងសាសន៍អ៊ីស្រាអែល ឲ្យឡើងទៅជាមួយ (អែសរ៉ា៧:២៨)។**

សង្ឃអែសរ៉ាបាននាំពួកបណ្ឌាជន២០០០នាក់ត្រឡប់មកវិញ។ ក្នុងចំណោមពួកបណ្ឌាជនទាំងនោះមិនមែនសុទ្ធតែជាអ្នកល្ងង់ទេ ពោលគឺភាគច្រើនជាអ្នកដឹកនាំតែម្តង។

ជំពូក៨ ផ្តល់អោយយើងដឹងនូវនាមឈ្មោះអ្នក ដែលធ្វើដំណើរត្រឡប់មកវិញជាមួយនឹងសង្ឃអែសរ៉ា។ សូមយើងកត់ចំណាំថា សង្ឃអែសរ៉ានាំយកមនុស្សត្រឡប់មកស្រុកវិញភាគច្រើនជាពួកសង្ឃលេវី។ ឯពួកនេធីនិមដែលត្រូវជាអ្នកបម្រើរបស់ពួកសង្ឃក៏ត្រឡប់មកនគរអ៊ីស្រាអែលជាមួយនឹងចៅហ្វាយរបស់គេដែរ។

ខាងក្រោមនេះ យើងឃើញបុគ្គលិកលក្ខណៈរបស់សង្ឃអែសរ៉ា។

**រួចមកខ្ញុំបានប្រកាសប្រាប់ ឱ្យមានការតមនៅមាត់ទន្លេអាហាវ៉ា នោះ ដើម្បីឱ្យយើងបានបន្ទាបខ្លួន នៅចំពោះព្រះនៃយើងរាល់ គ្នា ប្រយោជន៍នឹងសូមទ្រង់ឱ្យជំរង់ផ្លូវយើង នឹងកូនចៅ ហើយ របស់ទ្រព្យយើងទាំងអស់ផង (អែសរ៉ា៨:២១)។**

សង្ឃអែសរ៉ាបានអំពាវនាវសូមអោយប្រជាពលរដ្ឋ ដែលព្រមត្រឡប់មកនគរវិញ ធ្វើការអធិស្ឋាន និងតម ដើម្បីស្វែងរកព្រះហឫទ័យបំណងរបស់ព្រះជាម្ចាស់។ ការនេះកើតឡើងនៅមាត់ច្រាំងទន្លេអាហាវ៉ា។ សង្ឃអែសរ៉ាចង់ដឹងពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ សម្រាប់ជីវិតរបស់លោក ក៏ដូចជាជីវិតរបស់បណ្ដាជនដែលលោកដឹកនាំត្រឡប់មកស្រុកកំណើតវិញ។

**២២ដ្បិតដែលសូមទាហាន នឹងពលសេះ ពីស្តេចឱ្យទៅរាំងរាពួកខ្មាំងសត្រូវតាមផ្លូវ នោះនឹងនាំឱ្យខ្ញុំមានសេចក្តីខ្មាស ពីព្រោះយើងបានទូលស្តេចហើយថា ព្រះហស្តនៃព្រះរបស់យើងរាល់គ្នាសណ្ឋិតនៅនឹងអស់អ្នកដែលស្វែងរកទ្រង់ ដើម្បីនឹងប្រោសឱ្យបានសេចក្តីល្អ តែព្រះចេស្តានឹងសេចក្តីក្រេវក្រោធនៃទ្រង់ នោះ**

**ទាស់នឹងអស់អ្នកដែលបោះបង់ចោលទ្រង់វិញ ២៣ ដូច្នេះ យើងរាល់គ្នាបានតម ហើយសូមអង្វរដល់ព្រះនៃយើងពីដំណើរនេះ ហើយទ្រង់ក៏ទទួលស្តាប់តាមយើង (អែសរ៉ា៨:២២-២៣)។**

មុននឹងចាកចេញពីទីក្រុង ព្រះរាជាបានដណ្តឹងសួរដល់ហោរាអែសរ៉ាថា តើចង់បានពលទាហានសម្រាប់ការពារលោក និងក្រុមរបស់លោកតាមផ្លូវដែលឬទេ? បើតាមពាក្យដែលលោកបានមានប្រសាសន៍នៅក្នុងខខាងលើ លោកបានទូលថ្វាយដល់ស្តេចវិញថា ព្រះជាម្ចាស់គង់ជាមួយនឹងយើងខ្ញុំហើយ ដូច្នេះ យើងខ្ញុំមិនចាំបាច់សូមកងកម្លាំងប្រដាប់អាវុធទៅជាមួយនឹងយើងខ្ញុំទេ។ នៅក្នុងពេលដែលលោកឆ្លើយសំណួររបស់ព្រះរាជា លោកទុកចិត្តដល់ព្រះជាម្ចាស់ខ្លាំងណាស់។ ឥឡូវ ដល់មានមនុស្ស ២០០០នាក់ ឈរជាមួយនឹងលោក មានទាំងមនុស្សចាស់ មនុស្សពេញវ័យ មនុស្សកម្លោះក្រមុំ និងកុមារាកុមារីផង លោកយល់ថា ការធ្វើដំណើរត្រឡប់ទៅវិញ មានផ្លូវវែងឆ្ងាយណាស់។ គ្រោះថ្នាក់ក៏មានច្រើនណាស់ដែរ។ ដូច្នេះ លោកចាប់ផ្តើមមានការព្រួយបារម្ភ។ បើលោកត្រឡប់ទៅទូលដល់ស្តេចវិញថា លោកសូមយកទាហានចំនួនមួយ ឬពីរកងដើម្បីការពារដំណើររបស់លោក នោះលោកខ្លាចស្តេចមានបន្ទូលត្រឡប់មកវិញថា យើងគិតថាឯងទុកចិត្តដល់ព្រះជាម្ចាស់ ឥឡូវ ឯងបែរជាទុកចិត្តដល់យើងវិញ!

នៅក្នុងជីវិតរបស់គ្រីស្ទបរិស័ទ ជួនកាលយើងពូកែនិយាយថា យើងទុកចិត្ត

ដល់ព្រះជាម្ចាស់ ទោះបីកាលៈទេសៈយ៉ាងណានៅក្នុងជីវិតរបស់យើងក៏ដោយ។ យើងនឹងមិនបោះបង់ចោលព្រះជាម្ចាស់ជាដាច់ខាត។ ប៉ុន្តែ ដល់គ្រាមានរឿងកើតឡើង ទើបយើងដឹងថា ពាក្យសម្ដីរបស់យើងដែលពោលថាស្រឡាញ់ដល់ព្រះជាម្ចាស់ បែរជារត់ចោលយើងអស់រលីងទៅ។ សង្ឃអែសរ៉ា ជាបុគ្គលដែលមានលក្ខណៈបែបនេះ។ លោកទុកចិត្តដល់ព្រះជាម្ចាស់ពេលមិនទាន់មានរឿង។ ដល់ពេលមានរឿងកើតឡើង លោកសម្តែងការព្រួយបារម្ភ ដូចមនុស្សដទៃៗទៀតដែរ។ សង្ឃអែសរ៉ាពិតជាមនុស្សលោកមែន គឺលោកមិនមែនជាទេវតាមកពីស្ថានណាទេ។ តើលោកត្រូវធ្វើយ៉ាងដូចម្តេច ពេលប្រឈមមុខជាមួយនឹងស្ថានការណ៍ដ៏លំបាកនេះ? លោកបង្គាប់អោយពួកបណ្ដាជននាំគ្នាអធិស្ឋានតម និងសរសើរដល់ព្រះជាម្ចាស់។ លោកចង់បញ្ជាក់ប្រាប់បណ្ដាជនថា យើងទុកចិត្តដល់ព្រះជាម្ចាស់។ លោកចង់ទូលថ្វាយដល់ព្រះជាម្ចាស់ថា ព្រះអង្គអើយ ទីពឹងជ្រករបស់ទូលព្រះបង្គំមានតែព្រះអង្គមួយទេ។ ព្រះជាម្ចាស់បណ្ដោយអោយយើងធ្លាក់ចូលទៅក្នុងស្ថានការណ៍បែបនោះជាច្រើនលើកច្រើនសារ ដើម្បីអោយយើងចេះទុកចិត្តដល់ទ្រង់។ តើស្ថានការណ៍ជីវិតរបស់លោកអ្នកសព្វថ្ងៃនេះ មានភាពបែបណាដែរ? មានសង្ឃឹម ឬក៏គ្មានសង្ឃឹមច្រើនជាង? ចូរទុកចិត្តដល់ព្រះជាម្ចាស់ ទោះបីស្ថានការណ៍ជីវិតរបស់លោកអ្នកជួបប្រទះនឹងស្ថានការណ៍ ដូចលោកអ្នកកំពុងតែជួបប្រទះក្នុងពេលនេះយ៉ាងណាក៏ដោយ។ ព្រះជាម្ចាស់ទ្រង់មានព្រះហឫទ័យស្មោះត្រង់ ទោះបីយើងមិនស្មោះត្រង់ជាមួយនឹងទ្រង់ក៏ដោយចុះ។

**៣១ រួចមក នៅថ្ងៃទី១២ខែចេត្រ នោះយើងរាល់គ្នាបានធ្វើដំណើរ
ចេញពីទន្លេអាហាវ៉ា ដើម្បីនឹងទៅឯក្រុងយេរូសាឡិម ព្រះហស្ត
នៃព្រះរបស់យើងក៏សណ្ឋិតនៅជាមួយ ហើយទ្រង់ជួយឱ្យយើងរួច
ពីកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ នឹងពួកចោរដែលបង្កប់ខ្លួនតាមផ្លូវ
ផង ៣២ យើងរាល់គ្នាក៏បានដល់ក្រុងយេរូសាឡិម ហើយបាននៅទី
នោះអស់៣ថ្ងៃ (អែសរ៉ា៨:៣១-៣២)។**

ព្រះរាជាបានប្រគល់មាស ប្រាក់ និងគ្រឿងប្រដាប់ជាច្រើនដល់ក្រុមដែលត្រឡប់ទៅស្រុកវិញ។ មាស ប្រាក់ទាំងនោះ ប្រគល់អោយពួកសង្ឃដែលត្រូវមានភារៈការពារ។ ព្រះជាម្ចាស់ឃ្លាំមើលដំណើររបស់អែសរ៉ា និងពួករបស់លោក រហូតដល់លោកធ្វើដំណើរទៅដល់ទីកន្លែងដោយសុវត្ថិភាព។ នៅពេលក្រុមរបស់លោកធ្វើដំណើរទៅទីក្រុងយេរូសាឡិម លោកសម្រាកបីថ្ងៃ រួចហើយលោកយកភ័ស្តុភារដង្វាយទាំងអម្បាលមាណទៅតម្កល់ទុកនៅក្នុងព្រះវិហារ ដែលជាដំណាក់របស់ព្រះជាម្ចាស់។

**ឯពួកអ្នកដែលបានត្រឡប់ពីសណ្ឋានជាឈ្លើយមកវិញ គេក៏ថ្វាយដង្វាយដុតដល់ព្រះនៃសាសន៍អ៊ីស្រាអែល គឺគោឈ្មោល១២ឱ្យពួកអ៊ីស្រាអែលទាំងអស់ ព្រមទាំងចៀមឈ្មោល៩៦ កូនចៀម៧៧ នឹងពពែ១២ សំរាប់ជាដង្វាយលោះបាប នោះសុទ្ធតែជាដង្វាយ**

**ដុតថ្វាយដល់ព្រះយេហូវ៉ាទាំងអស់ (អែសរ៉ា៨:៣៥)។**

នៅក្នុងខខាងលើយើងឃើញមានពពែចំនួនដប់ពីរ ត្រូវយកមកដុតជាដង្វាយសម្រាប់ថ្វាយដល់ព្រះជាម្ចាស់។ តើហេតុអ្វីបានជាចាំបាច់ត្រូវប្រើពពែដប់ពីរ? ពពែដប់ពីរ គឺជាដង្វាយដែលត្រូវដុតថ្វាយដល់ព្រះជាម្ចាស់ធួននឹងអំពើបាបរបស់សាសន៍អ៊ីស្រាអែលទាំងដប់ពីរគ្រួសារ។ សាសន៍អ៊ីស្រាអែលអាចត្រឡប់មកនគររបស់ខ្លួនវិញរួចហើយគេបានថ្វាយដង្វាយអរព្រះគុណដល់ព្រះជាម្ចាស់ សម្រាប់ការដែលទ្រង់ធ្វើការទាំងអស់នោះ។ អរព្រះគុណដល់ព្រះជាម្ចាស់ ដែលទ្រង់តែងតែជួយដល់រាស្ត្ររបស់ទ្រង់ជានិច្ច។

យើងស្លេះការសិក្សាគម្ពីរអែសរ៉ាត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"